ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : វាលស្បូវ

ភូមិ : វាលស្បូវ

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : វាលស្បូវ

ភូមិ : វាលស្បូវ

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **វាលស្បូវ** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **២៦** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **វាលស្បូវ** មានទីតាំងស្ថិតនៅក្នុងភូមិ **វាលស្បូវ** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **១១០** នាក់ ស្រីចំនួន **២៩** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **២** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **១៧៤** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- សហការជាមួយជំនាញផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋច្បាប់ស្តីពីជលផល ហាមការកាប់ព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍ល្មើស និងការអប់រំបរិស្ថាន។
- ការចុះបញ្ជីសមាកជិកសហគមន៍សហគមន៍នេសាទ
- សហការជាមួយមន្ត្រីជំនាញចុះកំណត់ផែនទីកន្លែងនេសាទសហគមន៍នេសាទ
- ការធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- ការធ្វើកិច្ចប្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ
- រៀបចំជ្រើសរើសអ្នកស្ម័គ្រចិត្តចូលក្រុមល្បាតបានចំនួន ៣ក្រុមចំនួនសរុប១៥នាក់
- ការចុះយាមល្បាតក្នុងកន្លែងនេសាទសហគមន៍
- មានការប្រជុំក្នុងជួរគណៈកម្មការ និងក្រុមល្បាត២ រឺ៣ខែម្តង
- មានការអញ្ជើញចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ
- បានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះផ្សេងៗនៅខេត្តកំពង់ឆ្នាំង

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **១៧៤**គ្រួសារ ក្នុងនោះមាន **៨៩១**នាក់ប្រុស **៤៣៨**នាក់ ស្រី **៤៥៣** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៨៩១** នាក់ ខ្មែរឥស្លាម **គ្មាន** អាណិកជនវៀតណាម **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៣៤ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ៤ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៨ នាក់ ស្រី ១២ នាក់

- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ៣ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ៣ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរគ្មាន កំរិតថ្នាក់បឋមសិក្សាចំនួន **៨៥** នាក់ ស្រី **១៩** នាក់ កំរិតមធ្យមសិក្សាចំនួន **២១** នាក់ ស្រី **៩** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **៤** នាក់ ស្រី **២** នាក់។

**៩-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន:

- ធ្វើនេសាទចំនួន ១៥២ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ១៧៤ គ្រួសារ ទំហំ ១៤៥ ហិកតា
- ធ្វើវារីវប្បកម្មចិញ្ចឹមត្រីក្នុងស្រះចំនួន ៥៣ គ្រួសារ ទំហំ ៥ ហិកតា
- ដាំបន្លែចំនួន ៣០ គ្រួសារ ទំហំ ១.៥ ហិកតា
- ជាងផ្ទះចំនួន ១០ គ្រួសារ
- ធ្វើចំការចំនួន ១៧៤ គ្រួសារ ទំហំ ២២ ហិកតានៅលើផ្ទៃដីប្រាំងសរុបចំនួន ១៤៥ ហិកតា
- ធ្វើសិប្បកម្មត្បាញកន្ទាលចំនួន ៧០ គ្រួសារ
- លក់ដូរចំនួន ១២ គ្រួសារ
- កែច្នៃផលនេសាទធ្វើត្រីឆ្អើរ ប្រហុក និងផ្អកមានចំនួន ៤២គ្រួសារ
- បញ្ចូលអាគុយមានចំនួន ២ គ្រួសារ
- ជួលគោយន្តភ្ជួរដីមានចំនួន ១១ គ្រួសារ
- វត់ទូកដមានចំនួន ៤ គ្រួសារ
- ជួលម៉ាស៊ីនបោកស្រូវមានចំនួន ៣ គ្រួសារ
- ពេទ្យឆ្មបភូមិមានចំនួន ២ គ្រួសារ។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ ***វាលស្បូវ*** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៩**។ កន្លែងនេសាទសហគមន៍ ***វាលស្បូវ*** មានផ្ទៃដីទំហំ **៣៣១** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង ***សហគមន៍សិរីខ្វជ័យ***

- ខាងត្បូងទល់នឹង **ទន្លេធំ**
- ខាងកើតទល់នឹង **សហគមន៍នេសាទបាក់ភ្នំ**
- ខាងលិចទល់នឹង **សហគមន៍នេសាទកៀនឃ្លាំង**

**៩. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **វាលស្បូវ** មានបឹងចំនួន **២** ព្រែក **គ្មាន** ប្រឡាយមានចំនួ **២** ត្រពាំងចំនួន **៦** បៀចំនួន **គ្មាន** និងទំនប់មេទឹកចំនួន **៥**។

**តារាងទី ១: ឈ្មោះបឹង ត្រពាំង អាងទឹក និងប្រឡាយនៅក្នុងដែននេសាទសហគមន៍**

| ល.រ | ឈ្មោះកន្លែងនេសាទ ក្នុងដែននេសាទសហគមន៍ | ទំហំ (ហិកតា) | ពេលវេលាធ្វើនេសាទ (ខែ) |
|---|---|---|---|
| ១ | បឹងជាប់ជើង | ១៤ | វិច្ឆិកា-ឧសភា |
| ២ | បឹងវែង | ១៤.៧ | វិច្ឆិកា-ឧសភា |
| ៣ | ត្រពាំងរឿនកាយ | ០.៨ | មករា-មេសា |
| ៤ | ត្រពាំងស្មោរ | ២ | មករា-មេសា |
| ៥ | ត្រពាំងតាជុំ | ០.៥ | មករា-មេសា |
| ៦ | ត្រពាំងពូករស់ | ០.៣ | មករា-មេសា |
| ៧ | ត្រពាំងអៀន | ១.៧ | មករា-មេសា |
| ៨ | ត្រពាំងតាប៊ូច | ០.៥ | មករា-មេសា |
| ៩ | អាងទឹកតាពៅ | ៦ | មករា-មេសា |
| ១០ | អាងទឹកតាវ៉ែន | ៤ | មករា-មេសា |
| ១១ | អាងទឹកតាសន | ៤ | មករា-មេសា |
| ១២ | អាងទឹកវាលធំ | ១៩.៦ | មករា-មេសា |
| ១៣ | អាងទឹកជាប់ជើង | ១០ | មករា-មេសា |
| ១៤ | ប្រឡាយប៉ុលពត | ១៣០ ម៉ែត្រ | មករា-មេសា |

- ព្រៃលិចទឹកមានទំហំសរុប ៤៨ ហិកតា
- ព្រៃឈ្មោះ ជាប់ជើងទំហំ ១០ ហិកតា
- ព្រៃឈ្មោះ ប្រាំងលើទំហំ ១០ ហិកតា
- ព្រៃឈ្មោះ វាលធំទំហំ ១០ ហិកតា
- ព្រៃឈ្មោះ តាពៅទំហំ ១០ ហិកតា
- ព្រៃឈ្មោះ ត្រពាំងស្មោរទំហំ ៨ ហិកតា
- ដីទំនាបលិចទឹកនៅរដូវវស្សាមានទំហំសរុប **៣៣១** ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជ្រើសរើសកន្លែងអភិរកនៅក្នុងឯកសារជំនួយបច្ចេកទេសរបស់ការិយាល័យគាំទ្រគម្រោង នៃគម្រោងគ្រប់គ្រប់បរិស្ថានបឹងទន្លេសាប-ផ្នែកទី២ សហគមន៍នេសាទវាលស្បូវជ្រើសរើសបានសម្រេចជ្រើសផ្នែកកណ្តាលបឹងជាប់ជើង ទំហំ 0.៥ ហិកតា ដែលមានបណ្តោយ ១០០ម ទទឹង ៥០ម។

**ឃ.ធនធានជលផល**

- ប្រភេទត្រីមានៈ រ៉ស់ អណ្តែង ក្រាញ់ កាឡង់ ក្រម៉ម ឆ្តោ ច្រកែង កេះ ឆ្លាំង ឆ្លូង គល់រាំង ត្រសក់ ឆ្តោក ដំរី ខ្ជឹង ក្រុស កញ្ចុះ លិញ ចង្វារ ឆ្កិន ជន្ទាស់ភ្លុក កំភ្លៀវ ស្រកាក្តាម កំភ្លាញ អំពិលទុំ ផ្ទោង ខ្នាន់ ក្រពាត់ កាប ក្រឹម និងកញ្ជ្រូក។
- ប្រភេទវារីសត្វមានៈ ពស់ អណ្តើក ខ្យង គន្ធាយ ភេ ខ្លាត្រី ទាទឹក ខ្ទិក ក្អែកទឹក ប្រវឹក ត្រយ៉ង ទុង ក្រសា និងកុក។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិមានៈ រាំង ត្រស់ ត្នើក បន្លាយួន ពស់ទឹក ប្រលិត ឈូក ចំបូង រំចង់ ស្មាមចង្វា វល្លិស្គន់ ជន្ទល់ភ្នំ ភ្នំព្លែង បបួស ច្រកែង ត្រសេក និងត្នួរ។

**តារាងទី ២:**

| ត្រី | | | វារីសត្វ | | | វារីរុក្ខជាតិ | | | ព្រៃលិចទឹក | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះត្រី | កើន | ថយ | វារីសត្វ | កើន | ថយ | វារីរុក្ខជាតិ | កើន | ថយ | ព្រៃលិចទឹក | កើន | ថយ |
| ត្រីរ៉ស់ | ✓ | | ពស់ | | ✓ | ព្រលឹត | ✓ | | រាំង | | ✓ |
| អណ្តែង | ✓ | | អណ្តើក | | ✓ | ឈូក | ✓ | | ភ្នំភ្លើង | | ✓ |
| ក្រាញ់ | ✓ | | ខ្យង | | ✓ | ចំបូង | ✓ | | ភ្នែកត្រី | | ✓ |
| ក្រឡង់ | ✓ | | កន្ធាយ | | ✓ | រំចង់ | ✓ | | ច្រកែង | | ✓ |
| ក្រម៉ម | | ✓ | ភេ | | ✓ | ស្លាបច្រវ៉ា | ✓ | | ផ្ទោល | | ✓ |
| ដៀប | | ✓ | ខ្លាត្រី | | ✓ | វល្លិស្គួន | ✓ | | ថ្នាលមាន់ | | ✓ |
| ច្រកែង | ✓ | | ក្តាម | ✓ | | ជញ្ជាលភ្នំ | ✓ | | តាអូ | | ✓ |
| កែស | | ✓ | ទាទឹក | | ✓ | | | | ទានព្រៃ | ✓ | |
| ឆ្លាំង | ✓ | | ខ្ទិក | | ✓ | | | | ផ្គាំ | | ✓ |
| ឆ្លូញ | ✓ | | ក្អែកទឹក | | ✓ | | | | ខ្ទុំ | | ✓ |
| ក្បាលឡាន | ✓ | | ប្រវឹក | | ✓ | | | | តាសេក | | ✓ |
| ក្រុសមេម៉ាយ | ✓ | | ត្រយ៉ង | | ✓ | | | | ក្លៃ | | ✓ |
| កំពិស | | ✓ | ទង់ | | ✓ | | | | បបួយ | | ✓ |
| ឆ្តោក | | ✓ | ក្រសា | | ✓ | | | | អាទាំង | | ✓ |
| ដំរី | ✓ | | កុក | | ✓ | | | | ដៃខ្លា | | ✓ |
| ខ្ជឹង | ✓ | | កង្កែប | ✓ | | | | | កន្តក | | ✓ |
| ក្រុសខ្នងវែង | ✓ | | គីង្គក់ | ✓ | | | | |ល្បៀង | | ✓ |
| កញ្ចុះ | ✓ | | | | | | | | កណ្តាប់ចង្កេ | | ✓ |
| លិញ | ✓ | | | | | | | | ផ្តៅ | | ✓ |
| ចង្វា | ✓ | | | | | | | | កន្ទ្រែង | | ✓ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្អិន | ✓ | | | | | | | | ចង្កូមក្រពើ | | ✓ |
| ជន្ទាស់ភ្លុក | ✓ | | | | | | | | ស្មោ | | ✓ |
| កំភ្លៀវ | | ✓ | | | | | | | កាពៅ | | ✓ |
| ស្រកាក្ដាម | | ✓ | | | | | | | កំព្រៀម | | ✓ |
| កំភ្លាញ | ✓ | | | | | | | | ឆ្អឹងពស់ | | ✓ |
| អំពិលទំ | | ✓ | | | | | | | ប្របាច | | ✓ |
| ផ្ទោង | ✓ | | | | | | | | ត្រស់ | | ✓ |
| ខ្នាន់ | ✓ | | | | | | | | ក្របាស់ព្រៃ | | ✓ |
| ក្រពាត់ | | ✓ | | | | | | | ភ្នំភ្លាង | | ✓ |
| កាប | ✓ | | | | | | | | ថ្វាន់ទឹក | | ✓ |
| ចង្វាមូល | | ✓ | | | | | | | បន្ទាយួន | | ✓ |
| ចង្វាភ្លៀង | ✓ | | | | | | | | | | |
| ចង្វាបង្កួយ | | ✓ | | | | | | | | | |
| ក្រឹម | ✓ | | | | | | | | | | |
| កញ្ជូក | | ✓ | | | | | | | | | |
| កញ្ចុះក្ដោង | ✓ | | | | | | | | | | |

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

តាមការប៉ាន់ប្រមាណចំនួនអ្នកនេសាទដែលធ្វើការនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ តួរលេខបានបង្ហាញឱ្យឃើញថាៈ

- អ្នកនេសាទសរុបដែលរស់នៅក្នុងសហគមន៍មានចំនួន **៤៧៩** នាក់ ស្រី **២៥៩** នាក់ ក្នុងនោះមានៈ
  - អ្នកនេសាទជាសមាជិកសហគមន៍នេសាទ **១១០** នាក់ ស្រី **២៩** នាក់
  - អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **៣៦៩** នាក់

    ស្រី **២៣០** នាក់
- អ្នកនេសាទដែលមកពីខាងក្រៅ (ភូមិផ្សេងៗ) ចំនួន **១០** នាក់ ស្រី **គ្មាន**។

តាមរយៈការរកឃើញតួរលេខនៃចំនួនអ្នកនេសាទដែលធ្វើការនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ បានផ្ដល់គំនិតដល់ក្រុមកសាងផែនការមូលដ្ឋានឱ្យគិតអំពីការងារដែលត្រូវធ្វើនៅពេលខាងមុខ ដូចជាៈ ការផ្សព្វផ្សាយបន្តដើម្បីទទួលបានសមាជិកសហគមន៍នេសាទបន្ថែម និងការប្រមូលភាគទានសមាជិកសហគមន៍ ព្រមទាំងពីអ្នកនេសាទដែលមកពីខាងក្រៅសម្រាប់បម្រើការងារសហគមន៍។

### ខ. ឧបករណ៍នេសាទ

ការប៉ាន់ប្រមាណឧបករណ៍នេសាទដែលប្រើនៅក្នុងកន្លែងនេសាទសហគមន៍នឹងផ្ដល់គំនិតឱ្យសហគមន៍ដឹងថា តើមានឧបករណ៍នេសាទអ្វីខ្លះដែលល្មើសច្បាប់ និងរំលោភលើលក្ខន្តិកៈ-បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទកំពុងកើតមានឡើង? តើអ្នកណាជាអ្នកបង្កឡើង? ហើយថា តើសហគមន៍ត្រូវមានវិធានការយ៉ាងដូចម្ដេច ដើម្បីទប់ស្កាត់ការប្រើប្រាស់ឧបករណ៍ល្មើសទាំងនោះ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

**តារាងទី ៣:** **ឧបករណ៍នេសាទ**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង | ពេលវេលាប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មង | ត្បូង | ២(*) | ១១០ | ១៧.៥០០ម | ខែកញ្ញា-មីនា |
| សំណាញ់ | វង់ | ១ | ៤ | ៤វង់ | ខែកញ្ញា-តុលា |
| សន្ទូចរនង | សាង | ១(**) | ១០ | ៣០០០ផ្លែ | ខែកញ្ញា-វិច្ឆិកា |
| លបកំពិស | គ្រឿង | ៣០ | ១ | ៣០លប | ខែវិច្ឆិកា-ធ្នូ |
| លប | គ្រឿង | ១០ | ១ | ១០លប | ខែកញ្ញា-ធ្នូ |
| បង្កៃ | ផ្លែ | ៥០ | ៥០ | ១៥០០ផ្លែ | ខែធ្នូ-មីនា |
| សន្ទូចវាត់ | ផ្លែ | ១ | ៨២ | ៨២ | ខែកញ្ញា-តុលា |

**កំណត់សំគាល់:**

(*) – ១ ត្បូង=៨០ម៉ែត្រ

(**) - ១ សាង=៣០០ផ្លែ

**តារាងទី៤:** **ប្រភេទទូក-កាណូត**

| ល.រ | ប្រភេទទូក-កាណូត | ឯកតា | ចំនួន | ចំណុះ( គ.ក) | កំលាំងសេះ |
|---|---|---|---|---|---|
| ១ | ទូកឈើ | គ្រឿង | ៧០ | ២០០ | - |
| ២ | ទូកត្នោត | គ្រឿង | ៨០ | ១០០ | - |
| ៣ | កាណូត | គ្រឿង | ២០ | ២០០០ | ៣,៥-៧ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

**តារាងទី ៥:** **ឧបករណ៍នេសាទ**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង |
|---|---|---|---|---|
| មង | ត្បូង | ២(*) | ៨៥ | ១៣.៦០០ម |
| អញ្ចង | វង់ | ១(***) | ២ | ២វង់ |
| សន្ទូចរនង | សាង | ១(**) | ១៥ | ៤.៥០០ផ្លែ |

**កំណត់សំគាល់:**

(*) – ១ ត្បូង=៨០ម៉ែត្រ

(**) - ១ សាង=៣០០ផ្លែ

(***) - ១វង់=១៥ម៉ែត្រ

**តារាងទី ៦:** ប្រភេទទូក-កាណូត

| ល.រ | ប្រភេទទូក-កាណូត | ឯកតា | ចំនួន | ចំណុះ( គ.ក) | កំលាំងសេះ |
|---|---|---|---|---|---|
| ១ | កាណូត | គ្រឿង | ១០៥ | ២០០០ | ៣,៥-៧ |
| ២ | ទូកក្តោត | គ្រឿង | ៩៨ | ១០០ | - |

-ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

**តារាងទី ៧:** ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង |
|---|---|---|---|---|
| មង | ត្បូង | ២(*) | ១០ | ៣.២០០ម |
| សន្ទូចរនង | សាង | ១(**) | ១០ | ៣.០០០ផ្លែ |

**កំណត់សំគាល់:**

(*) – ១ ត្បូង=៨០ម៉ែត្រ

(**) - ១ សាង=៣០០ផ្លែ

**តារាងទី ៨:** ប្រភេទទូក-កាណូត

| ល.រ | ប្រភេទទូក-កាណូត | ឯកតា | ចំនួន | ចំណុះ( គ.ក) | កំលាំងសេះ |
|---|---|---|---|---|---|
| ១ | កាណូត | គ្រឿង | ៦ | ៥០០ | ៣-៧ |
| ២ | ទូកក្តោត | គ្រឿង | ៤ | ១០០ | - |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

**តារាងទី ៩:** ប្រភេទទូក-កាណូត

| ផលចាប់តាមប្រភេទឧបករណ៍ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ ( គិតជា គ.ក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| មង | ៤៣.១២៥ | ៥.៦២៥ | ៤៨.៧៥០ |
| សន្ទូចរនង | ៧៥០០ | ១៦៨៧.៥ | ៩១៨៧.៥ |
| លបកំពិស | - | ៨០ | ៨០ |
| លប | ២០ | ៦០ | ៨០ |
| បង្កៃ | ៤០០ | - | ៤០០ |
| សន្ទូចរាត់ | - | ១.០០០ | ១.០០០ |
| សំណាញ់ | - | ៥០០ | ៥០០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **វាលស្បូវ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាងទី ១០:**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងជាប់ជើង | ខែតុលា-មិថុនា | មង | ២០០ម | ៥គ្រួសារ | |
| | ខែតុលា-មិថុនា | សន្ទូចបង្កៃ | ២០០ផ្លែ | ២០គ្រួសារ | |
| | ខែតុលា-មិថុនា | អន្ទង | ២វង់ | ២គ្រួសារ | |
| | ខែតុលា-មិថុនា | លប | ១៥គ្រ | ៣គ្រួសារ | |
| បឹងវែង | ខែតុលា-មិថុនា | មង | ២០០ម | ៥គ្រួសារ | |
| | ខែតុលា-មិថុនា | សន្ទូចបង្កៃ | ២០០ផ្លែ | ២០គ្រួសារ | |
| | ខែតុលា-មិថុនា | អន្ទង | ២វង់ | ២គ្រួសារ | |
| | ខែតុលា-មិថុនា | លប | ១៥គ្រ | ៣គ្រួសារ | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាងទី ១១:**

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងជាប់ជើង | ១៤ហាត | ០,៥ហាត | ស្តារដោយកម្លាំងពលកម្ម | ខែ មេសា ២០០៩ | ខែ ឧសភា ២០០៩ | ៥.០០០ដូ |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាងទី ១២:**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងជាប់ជើង | ២ ហាត | រក្សាផលស្តុកត្រីមេពូជ និងជីវៈចំរុះគ្រប់ប្រភេទ | -ផ្សព្វផ្សាយ<br>-បោះស្លាកសញ្ញា<br>-ព័ន្ធបន្លាលួស<br>-ដាក់លូ<br>-បោះបង្គោល | ខែ ឧសភា ២០០៨ | ខែ កក្កដា ២០០៨ | ២.០០០ដូ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាងទី ១៣:**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅតំបន់វាលធំជាប់ជើង | ២ហាត | រាំង និងត្រស់ | -ផ្សព្វផ្សាយ<br>-បណ្តុះកូនឈើ<br>-បោះព្រំប្រទល់<br>-ដាំ និងបោះស្លាកសញ្ញា | ខែឧសភា ២០០៨ | ខែកក្កដា២០០៨ | ២.០០០ដូ |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

**តារាងទី ១៤:**

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ២៥ | ប្រា ឆ្ពិន និង អណ្តែង | ៣៧.៥០០កូន ១.៥០០ ដុល្លា | ខែ វិច្ឆិកា ២០០៨ | ខែសីហា ២០០៩ |

### គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

**តារាងទី ១៥:**

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកា | ខែមេសា ២០០៨ | ខែ ឧសភា ២០០៨ | ៦០.០០០៛ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលថវិកា | ខែមេសា ២០០៨ | ខែ ឧសភា ២០១០ | ១៥០.០០០៛ | |

### គ-៧ ផែនការសុខភាព និងអានាម័យ

**តារាងទី ១៦:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| បង្គន់អនាម័យ | ៥ | ៥ | ១៣០០ ដុល្លារ | ខែ មេសា ២០០៩ | ខែឧសភា២០០៩ |
| ថ្នាំបង់ទឹក Albet | ១៧៤ | ១៧៤កញ្ចប់ | ១៧៤ ដុល្លារ | ខែ មីនា ២០០៨ | ខែកុម្ភៈ២០១០ |

### គ-៨ ផែនការទ្រទ្រង់ជីវភាព

**តារាងទី ១៧:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ផ្តល់ទាចិញ្ចឹម | ២៥ | ៧៥ ក្បាល | ៤០០ ដុល្លារ | ខែ មករា ២០០៨ | ខែកុម្ភៈ ២០០៨ |
| ផ្តល់មាន់ចិញ្ចឹម | ២៥ | ៧៥ ក្បាល | ៤០០ ដុល្លារ | ខែ មករា ២០០៨ | ខែកុម្ភៈ ២០០៨ |
| ផ្តល់គោ | ៣ | ៣ក្បាល | ១២០០ ដុល្លារ | ខែ មករា ២០០៩ | ខែធ្នូ ២០១០ |
| ផ្តល់ជ្រូក | ១០ | ១០ ក្បាល | ៨០០ ដុល្លារ | ខែ មករា ២០០៩ | ខែកក្កដា២០០៩ |
| ផ្តល់គ្រាប់ពូជបន្លែ | ៥០ | ៥ ដុល្លា | ២៥០ ដុល្លារ | ខែ មការ ២០០៨ | ខែមករា២០១០ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទាលស្បូវ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

**តារាងទី ១៨៖**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ត្រួតពិនិត្យតាមបឹងជាប់ជើង និងបឹងវែង | ជំរុញឱ្យសមាជិកស.នប្រើប្រាស់ឧបករណ៍នេសាទតាមផែនការដែលបានកំណត់បឹងនីមួយៗ | ៦០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែតុលា-មីថុនា ២០០៨ | ខែតុលា-មីថុនា ២០១០ | |
| ២. ការកែលំអដែននេសាទ | ស្តាបឹងជាប់ជើងដោយអង្គពលកម្ម ០,៥ហិកតា | ទំហំស្តារបឹងជាប់ជើងចំនួន០,៥ហត នឹងមិនរីងនៅរដូវប្រាំងសម្រាប់រក្សាផលស្តុកត្រី | ៥០០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមេសា ២០០៩ | ខែឧសភា ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | ផ្សព្វផ្សាយ បោះស្លាកសញ្ញា ព័ទ្ធបន្ទាលួស ដាក់លួស និងបោះបង្គោល់ | ផលត្រី និងជីវចំរុះគ្រប់ប្រភេទនឹងមានការកើនឡើងវិញ | ២០០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែឧសភា ២០០៨ | ខែកក្កដា ២០០៨ | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | បោះស្លាកសញ្ញា បោះបង្គោល និង ផ្សព្វផ្សាយ បណ្តុះកូនឈើដាំ និងផ្សព្វផ្សាយ ល្បាត និងបោះស្លាកសញ្ញា | ទំហំព្រៃលិចទឹកចំនួន ២ហិកតាការពារទុកជាជំរកសម្រាប់ជីវចំរុះគ្រប់ប្រភេទ | ២០០០ ដុល្លារ | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែឧសភា ២០០៨ | ខែកក្កដា ២០១០ | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ផ្តល់កូនត្រីពូជដល់សមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទទីងទទួលបានកូនត្រីចំនួន៣៧៥០០ កូនដាក់ក្នុងស្រះ ចំនួន២៥ | ១៥០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែវិច្ឆកា ២០០៨ | ខែសីហា ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦. ផែនការថវិកាទ្រទ្រង់អភិវឌ្ឍន៍សហគមន៍ | ប្រមូលប្រាក់ភាគទានពីសមាជិកសហគមន៍នេសាទ ប្រាក់ភាគទានប្រចាំឆ្នាំ និងប្រាកភាគទានអ្នកនេសាទមកពីក្រៅ | សមាជិកសហគមន៍នេសាទ និងបង់ប្រាក់គ្រប់ចំនួន | ១៥០ ដុល្លា | -គណៈកម្មការសហគមន៍នេសាទ | ខែមេសា ២០០៨ | ខែឧសភា ២០១០ | |
| ៧. ផែនការសុខភាព និងអនាម័យ | ផ្តល់បង្គន់អនាម័យ និងថ្នាំ Albetទៅសមាជិកសហគមន៍នេសាទ | កាត់បន្ថយភាពកខ្វក់ និងជំងឺឆ្លងនៅក្នុងភូមិ និងជម្ងឺគ្រុនឈាម សត្វដល់សមាជិកសហគមន៍នេសាទចំនួន ១៧៤គ្រួសារ | ១៨៧៤ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែមីនា ២០០៨ | ខែកុម្ភៈ ២០១០ | |
| ៨. ផែនការទ្រទ្រង់ជីវភាពសមាជិកស.ន | ចិញ្ចឹមមាន់ ទា ជ្រូក គោ និងក្របី និងគ្រប់ពូជបន្លែ | សមាជិកសហគមន៍ចំនួន១១៣គ្រួសារនឹងអាចរកចំណូលបន្ថែមតាមរយៈការចិញ្ចឹមសត្វ | ២៨៣០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា ២០០៨ | ខែធ្នូ ២០១០ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | |
| ៧. ផែនការសុខភាព និងអនាម័យ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | |
| ៨. ផែនការទ្រទ្រង់សមាជិកសហគមន៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

បានឃើញ និងបញ្ជូនមក

លោកនាយ...រដ្ឋបាលជលផល.......

**នាយសង្កាត់រដ្ឋបាលជលផល**.....

.......ថ្ងៃទី...10.....ខែ...9.....ឆ្នាំ ២០០8

លេខ :............

បានឃើញ

**មេឃុំ**.....

.....ថ្ងៃទី...10....ខែ...9.....ឆ្នាំ ២០០8

លេខ :.........

...ថ្ងៃទី...9.....ខែ...9.....ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :..02..ខ.ក

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

.......ថ្ងៃទី...27...ខែ....11...ឆ្នាំ ២០០ 8

**នាយអធិការដ្ឋាន...រដ្ឋបាលជលផល**.....

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន...រដ្ឋបាលជលផល.....

.......ថ្ងៃទី...21...ខែ..10....ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**.....